# មេរៀនទី ១៤: ព្រះយេស៊ូវបង្រៀនអំពីផលផ្លែល្អ

## លូកា ៦:៤៣-៤៥

**គោលបំណង៖** ព្រះជួយយើងឲ្យមានការរីកចំរើន។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៥:៥** *"ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

សូមអានព្រះគម្ពីរ **លូកា ៦:៤៣-៤៥** ឲ្យលឺៗ។ តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីរក្សាទុកការល្អៗនៅក្នុងចិត្តរបស់អ្នកបាន? បើសិនជាអ្នកយល់ព្រមធ្វើតាមព្រះដោយអស់ពីចិត្ត ការល្អដែលអ្នកបានរក្សាទុកនៅក្នុងចិត្តរបស់យើងនឹងហូរទៅអ្នកដែលត្រូវការ។ ទូលសូមព្រះដើម្បីបង្ហាញអ្នកពីនរណាម្នាក់ ដែលអ្នកអាចបំរើនៅក្នុងក្រុមជំនុំរបស់អ្នកដែលមានសេចក្តីត្រូវការ ហើយបន្ទាប់មកសូមធ្វើរឿងល្អៗ និងជួយដល់បុគ្គលម្នាក់នោះ។

**ចំរៀង៖** ១. ខ្ញុំអាចធ្វើគ្រប់ការអ្វីបានទាំងអស់ ២. បើទ្រង់គង់ជាមួយ ៣. គ្រប់ទាំងអស់ខ្ញុំអាចធ្វើបាន

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ផ្កា មែក ដើម តាមកាយវិការ»

១. មុនចាប់ផ្តើមលេង គ្រូត្រូវណែនាំឲ្យកុមារធ្វើកាយវិការមួយចំនួនជាមុនសិន

- ដើម៖ យើងឈរឲ្យត្រង់ខ្លួន។
- ផ្កា៖ យើងយកដៃទាំងពីរទៅទ្រចង្កា។
- មែក៖ ដៃម្ខាងលើកឡើងលើ ហើយម្ខាងទៀតដាក់ទៅចំហៀងបង្ហាញពីការបែកមែក

២. គ្រូធ្វើជាឧទាហរណ៍ឲ្យកុមារមើល ដោយឲ្យកុមារធ្វើកាយវិការតាម (ដើមឈើ មែក ផ្កា) រហូតដល់ពួកគេចងចាំនូវកាយវិការទាំងនោះ។

៣. ឲ្យកុមារធ្វើកាយវិការតាមអ្វីដែលគ្រូបាននិយាយ (មែក) ប៉ុន្តែគ្រូធ្វើកាយវិកាយខុសពីអ្វីដែលគាត់និយាយ (ផ្កា) បើកុមារណាធ្វើខុសពីអ្វីដែលគ្រូបាននិយាយកុមារនោះនឹងចាញ់ល្បែងនេះ ហើយគាត់មិនមានសិទ្ធិលេង បន្តទេ សូមបន្តលេងល្បែងនេះរហូតដល់មានតែកុមារម្នាក់ប៉ុណ្ណោះ ដែលជាអ្នកឈ្នះ ។

៤. អ្នកដែលចាញ់យើងឲ្យគាត់មកខាងមុខ ដោយដាក់ពិន័យឲ្យអ្នកចាញ់រាំ ឬក៏ធ្វើ ដំណើរសត្វទា ឬសត្វស្វាជាដើម ។ល។

### ៤. ការណែនាំមេរៀន

តើប្អូនធ្លាប់ឃើញឪពុកម្តាយដាំបន្លែ ឬដើមឈើអ្វីដែរឬទេ? បើសិនជាធ្លាប់, បន្ទាប់ពីបានដាំរួច យើងនឹងត្រូវបន្តថែទាំបន្លែ ឬដើមឈើនោះដោយការស្រោចទឹកវា។ មួយរយៈក្រោយមក តើយើងសង្កេតឃើញមានអ្វីកើតឡើង?

គឺមានការដុះពន្លក លាស់ស្លឹក មានមែក ចេញផ្កា បន្ទាប់មកក៏មានក្តិបហើយ ចេញជាផ្លែ ។ **ព្រះបានជួយយើងឲ្យលូតលាស់ដូចជាដើមរុក្ខជាតិទាំងនោះដូច្នោះដែរ!** ថ្ងៃនេះយើងនឹងរៀនពីរឿងនៅក្នុងព្រះគម្ពីរ ដែលនិយាយអំពីដើមឈើដែលផ្តល់ផលផ្លែល្អ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយព្រះយេស៊ូវបាននិទានរឿងអំពីដើមឈើ។ ព្រះអង្គបាននិយាយពីរឿងនេះដើម្បីជួយយើងឲ្យយល់ពីរបៀបដែលព្រះជួយយើងឲ្យរីកចម្រើនបាន។ ព្រះអង្គបានមានបន្ទូលថា មានអ្នកថែចំការទំពាំងបាយជូរដ៏ឈ្លាសវៃម្នាក់។ ចំការទំពាំងបាយជូរបានបង្កើតផ្លែល្អ ហើយផ្អែមឆ្ងាញ់។ អ្នកថែចំការទំពាំងបាយជូរដ៏ឈ្លាសវៃម្នាក់នេះបានយកចិត្តទុកដាក់មើលថែចំការទំពាំងបាយជូរដោយក្តីស្រឡាញ់។ មែកទំពាំងបាយជូរខ្លះស្ងួត ហើយក្រៀមស្វិត។ មែកទាំងនោះមិនបង្កើតផលផ្លែទេ។ អ្នកថែចំការដឹងថាមែកទំពាំងបាយជូរ ដែលស្ងួតក្រៀមស្វិតគឺមិនល្អសំរាប់ដើមទំពាំងបាយជូរទេ ពីព្រោះមែកនោះនឹងទាញយកសារជាតិចិញ្ចឹមពីមែកទំពាំងបាយជូរដែលមានសុខ-ភាពល្អ។ ដូច្នេះអ្នកមើលថែចំការដ៏ឈ្លាសវៃម្នាក់នេះ បានកាត់មែក ដែលស្ងួត និងក្រៀមស្វិតនោះចេញ។ ធ្វើបែបនេះវានឹងជួយដល់ដើមទំពាំងបាយជូរឲ្យបង្កើតផលផ្លែបានល្អ។

ព្រះគម្ពីរប្រាប់យើងថាព្រះយេស៊ូវគឺជាដើមទំពាំងបាយជូរ ហើយព្រះវរបិតាគឺជាអ្នកមើលថែចំការគឺជាអ្នក ដែលថែទាំដើមទំពាំងបាយជូរ។ យើងទាំងអស់គ្នាប្រៀបដូចជាមែក ដែលនៅជាប់ជាមួយព្រះយេស៊ូវ។ ដើមទំពាំងបាយជូរជួយមែកទំពាំងបាយជូរដោយការបញ្ជូនទឹក និងជីរទៅកាន់មែកនីមួយៗ។ ប៉ុន្តែដើម្បីឲ្យយើងអាចរីកចំរើ-នលូតលាស់បាន លុះត្រាណាតែយើងនៅជាប់ជាមួយនឹងព្រះយេស៊ូវ បើសិនយើងមិននៅជាប់ជាមួយព្រះអង្គទេ យើងនឹងប្រៀបដូចជាមែកដែលក្រៀមស្វិតហើយស្លាប់តែម្តង។

ព្រះយេស៊ូវមានបន្ទូលថាមនុស្សមានការរីកចម្រើនលូតលាស់ដូចជាដើមឈើអ៊ីចឹង បើសិនជានៅក្នុងចិត្តរបស់ពួកគេមានរឿងល្អៗ ពួកគេនឹងធ្វើតែការល្អ ហើយបើនៅក្នុងចិត្តរបស់ពួកគេមានការអាក្រក់ពួកគេនឹងធ្វើនូវការអាក្រក់ផងដែរ។ ប៉ុន្តែព្រះជួយយើងឲ្យរីកចំរើនលូតលាស់ដើម្បីនឹងធ្វើការល្អ។ ពេលដែលយើងអនុញ្ញាតឲ្យព្រះអង្គថែទាំចិត្តរបស់យើង ព្រះអង្គនឹងធ្វើឲ្យយើងមានចិត្តល្អ ដូច្នេះយើងនឹងអាចធ្វើការល្អថ្វាយទ្រង់។ ការល្អដែលយើងធ្វើនោះហៅថាជាផលផ្លែរបស់យើង។

តើផលផ្លែអ្វីដែលអ្នកចង់ដាំវាឡើង? ការបង្ហាញនូវក្តីស្រឡាញ់ទៅកាន់អ្នកដទៃជួយកិច្ចការឪពុកម្តាយរបស់យើង ចែករំលែកការល្អជាមួយមិត្តភក្តិ ហើយទូលទៅព្រះពីការល្អដែលត្រូវធ្វើ។ ទាំងនេះគឺជាផលផ្លែល្អ! ព្រះយេស៊ូវបានប្រទាននូវអ្វីគ្រប់យ៉ាងដែលយើងត្រូវការ ដើម្បីឲ្យយើងមានសុភាពល្អ និងរឹងមាំ។ សូមទូលសុំទៅកាន់ព្រះជាម្ចាស់ដើម្បីជួយយើងឲ្យដាំនូវផលផ្លែដែលល្អ!

## ៦. សំនួរពិភាក្សា

១. នៅក្នុងសាច់រឿងនេះ តើអ្នកណាជាអ្នកថែចំការ? ជាដើម?និងមែកទំពាំងបាយជូរ? *ព្រះវរបិតាជាអ្នកថែចំការទំពាំងបាយជូរ ព្រះយេស៊ូវជាដើមទំពាំងបាយជូរ ហើយយើងជាមែកទំពាំងបាយជូរ*

២. តើមែកត្រូវធ្វើយ៉ាងណាដើម្បីទទួលបានផ្លែល្អ? *នៅឲ្យជាប់នឹងដើមទំពាំងបាយជូរ កុំដាច់ចេញពីដើមទំពាំងបាយជូរឲ្យសោះ*

៣. តើអ្វីខ្លះជាផលផ្លែដែលល្អ? *ធ្វើអំពើល្អដូចជា បង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃ ជួយធ្វើការងារឪពុកម្តាយ  ចែករំលែកជាមួយមិត្តភក្តិ មានទំនាក់ទំនងជាមួយព្រះ*

៤. តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបង្កើតឲ្យមានផលផ្លែល្អ? *នៅជាប់ជាមួយព្រះយេស៊ូវ អធិស្ឋាន អានព្រះគម្ពីរ បង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃ*

**៧. ខគម្ពីរចងចាំ        យ៉ូហាន ១៥:៥**

**៨. ហត្ថកម្ម        « តើអ្វីដែលជាផលផ្លែល្អ?»**

**ជម្រើសទី១**

**សម្ភារៈដែលត្រូវការ៖** ធ្វើដើមឈើមួយដោយប្រើមែកឈើជាច្រើន(សូមមើលទំព័រខាងក្រោមដើម្បីបោះពុម្ព) និងកាត់រូបផ្លែឈើ(សូមមើលទំព័រខាងក្រោមដើម្បីបោះពុម្ព)

**ជម្រើសទី២៖**កាត់រូបផ្លែឈើ(សូមមើលទំព័រខាងក្រោមដើម្បីបោះពុម្ព)ហើយប្រើផ្លែឈើទាំងនេះដើម្បីបង្កើតជាដើមឈើ(សូមមើលរូបនៅទំព័រខាងក្រោម)







១. បែងចែកកុមារជាក្រុមដោយក្នុង១ក្រុមមានគ្នាពី៤ ទៅ៥ នាក់

២. ឲ្យកុមារៗកាត់រូបផ្លែឈើ ហើយឲ្យពួកគេសរសេរពីផលផ្លែល្អដែលពួកគេអាចធ្វើបាន (ឧទាហរណ៍៖ កូនល្អ ការអត់ទោស អធិស្ឋាន មិត្តល្អ ចេះចែករំលែក)

៣. បើសិនជាកុមារត្រូវការគំនិតបន្ថែមពីផលផ្លែល្អដែលពួកគេចង់ធ្វើសូមប្រើ **កាឡាទី ៥:២២-២៣ “តែឯផលផ្លែនៃព្រះវិញ្ញាណវិញនោះគឺ សេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ។”** សូមលើកទឹកចិត្តកុមារឲ្យសរសេរផលផ្លែនៃព្រលឹងវិញ្ញាណទាំងអស់នេះហើយយកវាទៅបិតនៅ លើមែកឈើផងដែរ។



៤. បន្ទាប់ពីរយៈពេល៥នាទីសូមឲ្យកុមារឈប់សរសេរ ហើយឲ្យក្រុមនីមួយៗចែកចាយពីផលផ្លែ ដែលពួកគេបានសរសេរ។

៥. កុមារអាចយករូបផ្លែឈើរបស់ពួកគេទៅបិតលើមែកឈើមុនគេ។

**(សំរាប់ជំរើសទី២៖ ប្រើរូបផ្លែឈើរបស់កុមារដើម្បីធ្វើជាដើមឈើ)**



**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*










